ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៦៥៥
ចុះថ្ងៃទី ២៥-៧-២០១១
សាលដីកា
លេខៈ ៦២ ក្រ៥.ប
ចុះថ្ងៃទី ១៣-៩-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី២៣-៨-២០១៣ ដោយមានសមាសភាពដូចខាងក្រោមៈ

## ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

- លោក [redacted]

## ក្រឡាបញ្ជីសវនាការ

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៦៥៥ ចុះថ្ងៃទី ២៥-៧-២០១១ រវាងៈ

- ជនជាប់ចោទៈ

១- ឈ្មោះ [redacted] ឈុន ហៅ ឆក ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅភូមិច្រេះ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទីលំនៅមុនពេលចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ជានីតិជន ឃុំខ្លួន ថ្ងៃទី២២-០២-២០១០ ។

- មានមេធាវីការពារលោក [redacted] ជាន់ណា ។

២- ឈ្មោះ [redacted] សឿន ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរអ្នកបើកឡាន កើតនៅភូមិច្រេះ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន ជានីតិជន ឃុំខ្លួន ថ្ងៃទី២២-០២-២០១០ ។

៣- ឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរធ្វើស្រែ កើតនៅភូមិសំរោង ស្រុកសំរោង ខេត្តព្រៃវែង ទីលំនៅមុនពេលចាប់ខ្លួន ការដ្ឋានសំណង់



Scanned with CamScanner

[illegible] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន ជានីតិជន ឃុំខ្លួន ថ្ងៃទី២២-០២-២០១០ ។

- មានមេធាវីការពារលោក [redacted] ម៉ាច ។

ត្រូវចោទពីបទៈ ប្លន់, រំលោភសេពសន្ថវៈ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុមទី៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤-០២-២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥, ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ។

- ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិ [redacted] ។

- តាមបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-០២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឈុន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧ កប.៥ ចុះថ្ងៃទី១៤-០២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

- តាមបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សឿន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧ កប.៥ ចុះថ្ងៃទី១៤-០២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

- តាមបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឌី ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧ កប.៥ ចុះថ្ងៃទី១៤-០២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

## **៦រឿងហេតុមានដូចតទៅៈ**

កាលពីថ្ងៃទី១៤-០២-២០១០ មានជនល្មើសមានគ្នាបួននាក់ ឈ្មោះ [redacted] ឈុន ហៅ ឆក, ឈ្មោះ [redacted] សឿន, ឈ្មោះ [redacted] ឌី និងម្នាក់ទៀតឈ្មោះ [redacted] ចាន់នី ហៅ ចាន់នី បានធ្វើសកម្មភាពប្លន់រថយន្ត និងយកកាំភ្លើងភ្ជង់ចាប់ជនរងគ្រោះឈ្មោះ [redacted] រ៉ានី ជាមួយក្មួយស្រីតូចមួយដែលមានអាយុ ០៤ខែ ទៅជាមួយផង បានបើកចល័តរថយន្តចេញពីទីកើតហេតុទាំងយប់ ឯឈ្មោះ [redacted] ឌី ជាអ្នកចាំមើលផ្លូវ ។ ពេលប្លន់ឡានបានសម្រេចបក្ខពួកជនល្មើសទាំងបីនាក់ បានបើកឡានគេចទៅផ្សារបាត់ដឹង ពេលនោះឡានជិតអស់សាំងឈ្មោះ [redacted] ចាន់នី ក៏បានហៅទូរស័ព្ទទៅឈ្មោះ [redacted] ឌី ដោយយកទូរស័ព្ទជនរងគ្រោះម៉ាកណូគាស៊េរី ១២០២ ដោយដូរដាក់ស៊ីមថ្មីឲ្យយកសាំង ពួកខ្លួនចាំនៅភូមិរ៉ាស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ចាំអស់រយៈពេលពីរម៉ោង មិនឃើញឈ្មោះ [redacted] ឌី មក បក្ខពួកជនល្មើសក៏បើកឡានទៅមុខទៀតដល់សាលារៀនត្រពាំងលើក ភូមិត្រាចទង ឃុំសេនសាន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ក៏ឈប់ឡាននៅមុខសាលារៀន ហើយឈ្មោះ [redacted] សឿន និងឈ្មោះ [redacted] ចាន់នី បានទាញជនរងគ្រោះចេញពីឡានយកចូលទៅសាលារៀន ហើយចាប់រំលោភសេពសន្ថវៈម្នាក់ម្តងៗនៅភូមិត្រាចទង ឃុំសេនសាន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ជនជាប់ចោទបានចាប់រំលោភជនរងគ្រោះឈ្មោះ [redacted] រ៉ានី បានសម្រេចពីរនាក់ គឺឈ្មោះ [redacted] សឿន និងឈ្មោះ [redacted] ចាន់នី ហៅ ចាន់នី បន្ទាប់មកពួកជនល្មើសប្រទះ និងអ្នកដំណើរជិះម៉ូតូមកជិតខ្លួន ក៏គេចចេញបាត់ ពេលនោះជនរងគ្រោះក៏មានឱកាសដោះខ្លួនចេញមក ...



Scanned with CamScanner

ប៉ូលីសមត្ថកិច្ចឲ្យជួយចាត់ការស្វែងរកជនជាប់ចោទ ។ លុះស្អែកឡើងទើបសមត្ថកិច្ចចាប់ខ្លួនបានជនល្មើសជាបន្តបន្ទាប់បញ្ជូនមកតុលាការ ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៧ កបឥ ចុះថ្ងៃទី១៤-០២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា:

១- កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ឈុន ហៅ ឆក ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] សឿន ភេទប្រុស អាយុ២៩ឆ្នាំ, ឈ្មោះ [redacted] ឌី ភេទប្រុស អាយុ៣០ឆ្នាំ និងឈ្មោះ [redacted] ចាន់នី ហៅ ចាន់នី ភេទប្រុស កើតឆ្នាំ១៩៨៧ ដែលជាប់ចោទពីបទ: វិលោភសេពសន្ថវៈ និងប្លន់ តាមមាត្រា ៦,៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋមកជាបទ វិលោភសេពសន្ថវៈ និងអំពើលួច (ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើ ហឹង្សា) តាមមាត្រា ២៣៩, មាត្រា ២៤០, មាត្រា ៣៥៣ និងមាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

២- ឲ្យឈ្មោះ [redacted] ឌី ភេទប្រុស អាយុ៣០ឆ្នាំ និងឈ្មោះ [redacted] ឈុន ហៅ ឆក ភេទប្រុស អាយុ២០ឆ្នាំ រួចខ្លួនពីបទចោទប្រកាន់ពីបទ: វិលោភសេពសន្ថវៈ ប្រព្រឹត្តនៅក្រុម៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា ២៣៩ និងមាត្រា ២៤០ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

៣- ផ្តន្ទាទោសលើឈ្មោះ [redacted] សឿន ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) និងពិន័យជាប្រាក់ ២.០០០.០០០រៀល (ពីរលានរៀល) ប្រាក់នេះដាក់ចូលថវិការដ្ឋ ។

ពីបទ: អំពើលួច (ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហឹង្សា), វិលោភសេពសន្ថវៈ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុម៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១០ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧, មាត្រា ២៣៩, មាត្រា ២៤០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ ។

៤- ផ្តន្ទាទោសលើឈ្មោះ ពេជ្រ ចាន់នី ហៅ ចាន់នី ភេទប្រុស កើតឆ្នាំ១៩៨៧ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន និងពិន័យជាប្រាក់ ២.០០០.០០០រៀល(ពីរលានរៀល) ប្រាក់នេះដាក់ចូលជាថវិការដ្ឋ ។

ពីបទ: អំពើលួច (ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហឹង្សា), វិលោភសេពសន្ថវៈ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុម៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១០ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧, មាត្រា ២៣៩, មាត្រា ២៤០ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ ។

៥- ផ្តន្ទាទោសលើឈ្មោះ [redacted] ឈុន ហៅ ឆក ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ឌី ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារម្នាក់ៗកំណត់ ១០ឆ្នាំ (ដប់ឆ្នាំ)



Scanned with CamScanner

និងពិន័យជាប្រាក់ចំនួន ២.០០០.០០០រៀល (ពីរលានរៀល) ក្នុងម្នាក់ៗ ប្រាក់នេះដាក់ចូលជាថវិការដ្ឋ ។

ពីបទៈ អំពើលួច (ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា) និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុម៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១០ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ ។

៦- ឲ្យឈ្មោះ [redacted] ឈុន ហៅ ឆក, ឈ្មោះ [redacted] សឿន, ឈ្មោះ [redacted] ឌី និងឈ្មោះ [redacted] ចាន់នី សងសំណង និងជម្ងឺចិត្តឲ្យទៅឈ្មោះ ពិន រ៉ានី ជាជនរងគ្រោះ បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងម្នាក់ៗជាប្រាក់រៀលចំនួន២.០០០.០០០រៀល (ពីរលានរៀល) សុំលើសពីនេះច្រានចោល ។

៧- សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី២៥-០១-២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៤-០២-២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឈុន ហៅ ឆក, ឈ្មោះ [redacted] សឿន, ឈ្មោះ [redacted] ឌី មេធាវីការពារជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់នី ហៅ ចាន់នី ។

- ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-០២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឈុន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧ កប.៥ ចុះថ្ងៃទី១៤-០២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សឿន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧ កប.៥ ចុះថ្ងៃទី១៤-០២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឌី ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧ កប.៥ ចុះថ្ងៃទី១៤-០២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

- បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី១៧-១០-២០១១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

- បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី០៨-១១-២០១១ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] ឌី (វត្តមាន)
- ជនជាប់ចោទឈ្មោះ [redacted] ឈុន, [redacted] សឿន (អវត្តមាន)
- លោក [redacted] ជាន់ណា មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ឈុន (វត្តមាន)
- លោក [redacted] ម៉ាច មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ឌី, [redacted] សឿន (វត្តមាន)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ានី (អវត្តមាន)



Scanned with CamScanner

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ឈុន, [redacted] សឿន

- ជនជាប់ចោទឈ្មោះ [redacted] ឌី បានឆ្លើយថា ខ្លួនប្ដឹងឧទ្ធរណ៍មកនេះ ព្រោះខ្លួនមិនសុខចិត្តដោយចោទខ្លួនថា ជាមេក្លោងមុនពេលកើតហេតុជួបគ្នាផឹកទឹកត្នោតជូរក៏ឮពួកវាថា មានផែនការប្លន់រួចខ្លួនក៏ឆ្លើយថា មិនចូលរួមទេ ហើយខ្លួនក៏ទៅរត់ម៉ូតូឌុបទៅ ។ ថ្ងៃកើតហេតុខ្លួនមិនបានចូលរួមប្រព្រឹត្តទេ ខ្លួនស្គាល់ឈ្មោះ [redacted] ឈុន និង [redacted] សឿន ទើបតែបាន ០១ខែប៉ុណ្ណោះ ។ ថ្ងៃមួយពួកវាបានឲ្យខ្លួនឌុបវាទៅដាក់នៅសួន ដើម្បីរៀបគំរោងការប្លន់ ។ កាំភ្លើងជារបស់ឈ្មោះ [redacted] ចាន់នី ទេ ហើយខ្លួនសូមទទួលស្គាល់អង្គហេតុ ។ សំណូមពរ សុំឲ្យតុលាការឲ្យខ្លួនបានរួចខ្លួន ពីព្រោះខ្លួនអនុវត្តទោសយូរឆ្នាំមកហើយ ។

## តំណាងមហាអយ្យការសន្និដ្ឋានថា:

សំអាងហេតុរបស់សាលាដំបូងដែលសម្រេចមកមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ សុំតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៧ កប.៥ ចុះថ្ងៃទី១៨-០២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកដដែល ។

## មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋាន:

- លោក [redacted] ម៉ាច មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ឌី និង [redacted] សឿន សន្និដ្ឋានថា: សុំឲ្យក្រុមប្រឹក្សាពិនិត្យ ពិចារណា លើកូនក្ដីខ្លួនផង ព្រោះកូនក្ដីខ្លួនទើបប្រព្រឹត្តលើកទី១ ខ្វះការពិចារណា និងគ្មានចំណេះដឹង ។

- លោក [redacted] ជាន់ណា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ឈុន សន្និដ្ឋានថា ទាក់ទងនឹងការប្រើប្រាស់អាវុធ មិនមានការពាក់ព័ន្ធនឹងកូនក្ដីខ្លួនទេ ។ សំណូមពរ សុំឲ្យកូនក្ដីខ្លួនរួចផុតពីបទចោទប្រកាន់ ព្រោះកូនក្ដីខ្លួនបានសារភាពថាបានចូលរួម ប៉ុន្តែមិនទាន់បានប្រព្រឹត្តបទល្មើសទេ ។

- ក្រោយពីបានស្ដាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ឈុន, [redacted] សឿន
- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ឌី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍យល់ឃើញថា:

១- បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-០២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឈុន, បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សឿន និងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឌី ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចជំនុំជម្រះបាន ។

២- ជនជាប់ចោទឈ្មោះ [redacted] ឈុន ហៅ ឆក, ឈ្មោះ [redacted] សឿន និងឈ្មោះ លីវ ឌី ពិតជាទទួលរងនូវទណ្ឌកម្មម្នាក់ៗចំនួន ១០ឆ្នាំ និងឈ្មោះ អ៊ូ សឿន ទទួលរងនូវទណ្ឌកម្ម...



Scanned with CamScanner

កំនត់ចំនួន ១៥ឆ្នាំ តាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ១៧ កប.៥ ចុះថ្ងៃទី១៤ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ពីបទៈ ប្លន់, រំលោភសេពសន្ថវៈ និងប្រើប្រាស់អាវុធខុសច្បាប់ តាមបញ្ញត្តិមាត្រា ៥, ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និង មាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ កាលពីថ្ងៃទី១៤-០២-២០១០ ប្រាកដមែន ។

៣- នៅចំពោះមុខសាលាឧទ្ធរណ៍ជនជាប់ចោទឈ្មោះ លីវ ឌី ជាជនល្មើសម្នាក់ក្នុងចំនោមបក្ខពួករបស់ខ្លួនបានឆ្លើយសារភាពទទួលស្គាល់អង្គហេតុថា ខ្លួនពិតជាបានចូលរួមប្រព្រឹត្តបទល្មើសជាមួយបក្ខពួករបស់ខ្លួនដែលមានតួនាទីយាមផ្លូវប៉ុណ្ណោះ រីឯអាវុធខ្លីពុំមែនជារបស់ខ្លួនឡើយ ខ្លួនមិនជិះឡានទៅជាមួយគេទេ ហើយក៏ពុំចូលរួមរំលោភសេពសន្ថវៈទៅលើជនរងគ្រោះដែរ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ឈុន ហៅ ឆក តាមអង្គហេតុ និងចម្លើយបក្ខពួករបស់គេឈ្មោះ [redacted] ចាន់នី និងឈ្មោះ [redacted] ឌី បញ្ជាក់ថាអាវុធដែលប្រើប្រាស់ជាមធ្យោបាយប្រព្រឹត្តបទល្មើសនោះ ពុំមែនជាអាវុធរបស់ពួកគេទេ បើតាមការបញ្ជាក់របស់ជនជាប់ចោទឈ្មោះ [redacted] ឌី ថា ខ្លួនខ្ចីពីឈ្មោះ [redacted] សុខា នៅផ្ទះជូលផ្សារដើហុយ សម្រាប់បក្ខពួករបស់ខ្លួនធ្វើសកម្មភាពតាមគម្រោងរបស់ខ្លួនដែលរៀបចំដូចនេះទោះបីជនជាប់ចោទឈ្មោះ [redacted] ឌី ខិតខំឆ្លើយបដិសេធថា ខ្លួនពុំមែនជាមេក្លោង ឬពុំបានប្រើប្រាស់អាវុធក៏ដោយ តែនៅដំណាក់ស៊ើបអង្កេតនៅសមត្ថកិច្ច និងចៅក្រមស៊ើបសួរចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឌី មានអានុភាពជាភស្តុតាងដ៏រឹងមាំមិនអាចប្រកែកបាន ។

៤- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ឌី, ឈ្មោះ [redacted] ឈុន និងឈ្មោះ [redacted] សឿន ពីបទៈ ប្លន់, រំលោភសេពសន្ថវៈ និងប្រើប្រាស់អាវុធខុសច្បាប់ តាមមាត្រា ៥, ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ ប៉ុន្តែដោយក្រមព្រហ្មទណ្ឌចូលជាធរមាន គប្បីលើកយកមាត្រា ២៣៩ និង ៣៥៧ នៃក្រមព្រហ្មទណ្ឌមកជំនួសមាត្រា ៥, ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋវិញ ដើម្បីជាប្រយោជន៍ច្បាប់ ។

៥- សាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុបញ្ជាក់មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដោយពុំចាំបាច់សរសេរសំអាងហេតុដដែលនោះបញ្ជាក់សារជាថ្មីទៀតទេ ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ១៧ កប.៥ ចុះថ្ងៃទី១៤-០២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-០២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឈុន, បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សឿន និង បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឌី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

VSK

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៧ កប.៥ ចុះថ្ងៃទី១៤-០៦-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣- បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤- សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៣-៨-២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឌី មេធាវីការពារជនចាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សឿន, [redacted] ឈុន និងដើមបណ្ដឹងរដ្ឋប្បវេណី ប្រកាសជាសាធារណៈ នៅថ្ងៃទី១៣-៩-២០១៣ ។

- បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

សាលដីកានេះបានចូលជាស្ថាពរ និងមានអានុភាពអនុវត្តទៅលើឈ្មោះ [redacted] ឌី តែប៉ុណ្ណោះ ក្រៅពីនេះពុំមានអានុភាពទេ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយ សហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី...... ខែ...... ឆ្នាំ២០១៥
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner